**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខៈ** ៩៨៩ ស.ជណ

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជំរាបមក**

- **ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
- **ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តម ទី សុគន្ធ ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានរដ្ឋបាល ព្រៃឈើ**

**កម្មវត្ថុ** : ករណីសំណើសុំការគាំទ្រដ៏ខ្ពង់ខ្ពស់ពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សំរាប់គំរោងឥណទានកាបោនព្រៃឈើនៅព្រះរាជាណាចក្រកម្ពុជា។

**យោង** : -លិខិតចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០០៨ របស់លោកបណ្ឌិត Mark Poffenberger នាយកប្រតិបត្តិនៃអង្គការសហគមន៍ ព្រៃឈើអន្តរជាតិ ( CFI )

-លិខិតចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០០៨ របស់ឯកឧត្តម ទី សុគន្ធ ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

-ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ ២០០៨ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីមានកិត្តិយស សូមជំរាបជូន ឯកឧត្តមមេត្តាជ្រាបថា : ចំពោះករណីនេះរាជរដ្ឋាភិបាល បានសម្រេចយល់ព្រមតាមសំណើដូចខាងក្រោម :

១-ចាត់តាំងរដ្ឋបាលព្រៃឈើ ជាភ្នាក់ងារលក់កាបោនព្រៃឈើកម្ពុជា ជាមួយអង្គការសហគមន៍ ព្រៃឈើអន្តរជាតិ CFI ។

២-រាជរដ្ឋាភិបាលកម្ពុជា ដែលជាអ្នកលក់កាបោនព្រៃឈើទទួលខុសត្រូវជួយ ធ្វើឱ្យសម្រេចបាន លក្ខខណ្ឌក្នុងកិច្ចសន្យា " លក់កាបោន " ជាមួយអ្នកទិញ ។

៣-មានអនុស្សារណៈយោគយល់(MOU) រវាងអង្គការសហគមន៍ព្រៃឈើអន្តរជាតិនិងរាជរដ្ឋាភិបាលកម្ពុជា

PSSD 5/16/2008

ដែលតំណាងដោយរដ្ឋបាលព្រៃឈើដែលនឹងអាចអនុញ្ញាតឱ្យអង្គការ សហគមន៍ ព្រៃឈើអន្តរជាតិ CFI កំណត់ស្វែងរកអ្នកទិញ និងសិក្សាពីលក្ខខណ្ឌ និងតម្លៃ កាបោន ដែលនឹងត្រូវពិនិត្យ និងអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជាសំរេចនៅក្នុង អនុស្សារណៈយោគយល់ MOU ថា ចំណូលដែលបានពីការលក់សារជាតិកាបោននៃគំរោងឥណទានកាបោនសំរាប់ សហគមន៍ព្រៃឈើ និងត្រូវប្រើប្រាស់ដើម្បី :

ក-កែលំអរគុណភាពព្រៃឈើ

ខ-ផ្តល់ផលប្រយោជន៍ជាអតិបរិមាដល់សហគមន៍មូលដ្ឋានដែលបានចូលរួមក្នុងសកម្មភាពគំរោង

គ-សិក្សាកំណត់សក្តានុពលនៃ ទីតាំងគំរោងឥណទានកាបោនព្រៃឈើ REDD ថ្មី

៤-ចំណូលពីគំរោងកាបោនព្រៃឈើ REDD នឹងចូលតាមរយៈក្រុមការងារបច្ចេកទេស កំណែទំរង់ព្រៃឈើ ក្នុងរយៈពេល៥ ឆ្នាំដំបូងរបស់គំរោង ។

៥-ប្រគល់ភារកិច្ចឱ្យ រដ្ឋបាលព្រៃឈើធ្វើជាតំណាង រាជរដ្ឋាភិបាលកម្ពុជា ក្នុងការងាររៀបចំចាត់ចែងលក់កាបោនព្រៃឈើកម្ពុជា ដោយត្រូវមានការពិគ្រោះយោបល់ ក្នុងក្រុមការងារបច្ចេកទេសកំណែទំរង់ព្រៃឈើ តាមការចាំបាច់ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តម មេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តម ទទួលនូវសេចក្តីគោរពរាប់អានដ៏ស្មោះពីខ្ញុំ ។៸

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

ប្រាក់ សុខុន

**ចម្លងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រដ្ឋបាលព្រៃឈើ
- អង្គការសហគមន៍ព្រៃឈើអន្តរជាតិ CFI
- ក្រុមការងារបច្ចេកទេសកែទំរង់ព្រៃឈើ( TWGFE )
- ឯកសារ-កាលប្បវត្តិ